# កម្ពុជាក្រោម និងក្តីឈឺចាប់ក្នុងប្រវត្តិសាស្ត្រ

***ឡុងបិច : សុភាពុទ្ធិ***

ចាប់តាំងពីបារាំងកាត់ដីកម្ពុជាក្រោមឱ្យយួនត្រួតត្រារហូតដល់សព្វថ្ងៃមានរយៈពេល៥៩ឆ្នាំហើយ ។ បងប្អូនខ្មែរកម្ពុជាទាំងនោះត្រូវអាជ្ញាធរយួនប្រមាថមើលងាយដូចសត្វធាតុ និងព្យាយាមបំបាត់ទំនៀមទំលាប់ប្រពៃណី ភាសា អក្សរខ្មែរតាមរយៈរូបភាពផ្សេងៗ ។

ដោយមើលឃើញពីការឈឺចាប់បែបនេះ



លោក ថាច់ សេដ្ឋា ចូលគាល់ព្រះមហាក្សត្រ

បុព្វបុរសខ្មែរបានក្រោកឡើងទាមទារសិទ្ធិសេរីជាបន្តបន្ទាប់ ប៉ុន្តែគួរឱ្យសោកស្តាយ ការតស៊ូទាំងនោះត្រូវបរាជ័យ ហើយត្រូវយួនចាប់ធ្វើទារុណកម្ម និងសម្លាប់គ្មានត្រាប្រណី ។ ពេលនេះបងប្អូនខ្មែរកម្ពុជាក្រោមក្លាយជាជនជាតិភាគតិចរស់នៅលើទឹកដីរបស់ខ្លួន ហើយត្រូវពួកយួនធ្វើបាបគ្រប់រូបភាពយ៉ាងអយុត្តិធម៌ ។

ខាងក្រោមនេះជាបទសម្ភាសន៍ខ្មែរប៉ុស្តិ៍ជាមួយនឹងលោក ថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម ដែលមានខ្លឹមសារដូចខាងក្រោម :

**+ តើសហគមន៍ខ្មែរកម្ពុជាក្រោមបង្កើតឡើងតាំងពីឆ្នាំណា ?**

-សហគមន៍ខ្មែរកម្ពុជាក្រោម តាមពិតបានបង្កើតឡើងតាំងពីឆ្នាំ២០០០ កាលនោះគេហៅថា "មូលនិធិខ្មែរកម្ពុជាក្រោម" ប៉ុន្តែ យើងដាក់ច្បាប់ទៅរដ្ឋាភិបាលមិនទទួលយក ។ ក្រោយមកក៏ប្រែឈ្មោះជា "សហគមន៍ខ្មែរកម្ពុជាក្រោម" នៅឆ្នាំ២០០៣ ដោយសារតែមានប្រតិកម្មពីក្រសួងការបរទេសយួន ដែលចាត់ទុកខ្មែរក្រោមនៅកម្ពុជាជាប្រតិកិរិយាប្រឆាំងនឹងរដ្ឋាភិបាលយួន ប្រារព្ធពិធីបាត់ទឹកដី ។

**+ តើបងប្អូនខ្មែរកម្ពុជាក្រោមនៅកម្ពុជា និងស្រុកយួនមានប៉ុន្មាននាក់ ?**

-ខ្មែរក្រោមដែលរស់នៅកម្ពុជាមានជាង១លាននាក់ បើសិនយើងស្រង់ឱ្យល់អិតមានច្រើនជាងនេះ ពីព្រោះពួកគាត់មួយចំនួនបានប្តូរត្រកូល ដើម្បីរស់នៅបានស្រួលជាមួយអាជ្ញាធរ ។ ចំណែកខ្មែរក្រោមដែលរស់នៅស្រុកយួនមានប្រមាណ១៤លាននាក់ ស្មើខ្មែរយើងនៅកម្ពុជាដែរ ។

**+ តើស្ថានភាពរស់នៅរបស់បងប្អូនខ្មែរកម្ពុជាក្រោមទាំងនៅកម្ពុជា និងយួនជួបការលំបាកយ៉ាងណាខ្លះ ?** ( តនៅទំព័រទី១១ )

# កម្ពុជាក្រោម និងក្តីឈឺចាប់ក្នុងប្រវត្តិសាស្ត្រ

-ខ្មែរក្រោមនៅកម្ពុជាជួបការលំបាកច្រើនណាស់ ដោយសារតែរដ្ឋាភិបាលហាក់ដូចជាមានអាថិកំបាំង



ព្រះសង្ឃខ្មែរកម្ពុជាក្រោមចូលរួមប្រារព្ធពិធីខួបអនុស្សាវរីយ៍លើកទី ៥៩ នៃការបាត់បង់ទឹកដី



លោក ថាច់ សេដ្ឋា ប្រធានសមាគមមិត្តខ្មែរកម្ពុជាក្រោម

អ្វីមួយនឹងយួន ពីព្រោះខ្មែរក្រោមដែលមករស់នៅទីនេះ គឺពួកគាត់ពុំបានទទួលសិទ្ធិរស់នៅជាប្រជា-ពលរដ្ឋតាមរដ្ឋធម្មនុញ្ញក្នុងមាត្រាទី៣៣ទេ ។

-អាជ្ញាធរក្នុងមូលដ្ឋានខ្លះថា គ្មានអត្តសញ្ញាណមិនច្បាស់លាស់ ។ ចំណែកក្រសួងមហាផ្ទៃក៏មិនបង្កលក្ខណៈងាយឱ្យខ្មែរក្រោមមានអត្តសញ្ញាណទេ ហើយបើចង់បានត្រូវប្តូរទីលំនៅថា កើតនៅខេត្តតាកែវ, កំពត ឬស្វាយរៀងទើប គេធ្វើឱ្យ ។

ចំណែកព្រះសង្ឃខ្មែរកម្ពុជាក្រោម ដែលមករៀនក៏ពិបាកទាំងសាលារៀន និងវត្តគង់ ក៏គេពុំចង់ឱ្យដែរ ។ នេះគឺជាយុទ្ធសាស្ត្រដែលយួនធ្វើឱ្យខ្មែរក្រោម និងកណ្តាលឈ្លោះគ្នា ដូចករណីព្រះសង្ឃ ទីម សាខន ត្រូវព្រះសង្ឃខ្មែរចាប់ផ្សឹកបញ្ជូនទៅកាត់ទោសនៅយួនជាប់ពន្ធនាគារយ៉ាងអយុត្តិធម៌ ។

រីឯខ្មែរកម្ពុជាក្រោមរស់នៅស្រុកយួននោះ រងទុក្ខវេទនាខ្លាំងណាស់ ត្រូវអាជ្ញាធរយួនធ្វើបាបគ្រប់រូបភាព និយាយឱ្យខ្លីទុក្ខសោករបស់បងប្អូនកម្ពុជាក្រោម គឺជាទុក្ខសោករបស់មនុស្សជាតិធ្លាប់បានជួបប្រទះ គឺគ្មានការឈឺចាប់ណាជាងការបាត់បង់ទឹកដីរស់នៅលើទឹកដីខ្លួន ហើយក្លាយជាជនជាតិភាគតិចនោះទេ ។ ជាពិសេសនៅឆ្នាំ១៩៨៤-១៩៨៥ យួនបានអនុវត្តរបបប្រល័យពូជសាសន៍លើខ្មែរកម្ពុជាក្រោមយ៉ាងរង្គាល គឺចាប់អ្នកស្នេហាជាតិយកទៅធ្វើទារុណកម្មចាក់ថ្នាំសំលាប់ក្នុងពន្ធនាគារជាបន្តបន្ទាប់ ។

**+តើការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៥៩ នេះ ក្នុងគោលបំណងអ្វី ?**

-តាមធម្មតាចាប់តាំងពីឆ្នាំ២០០០មក សហគមន៍ខ្មែរកម្ពុជាក្រោម តែងប្រារព្ធទិវានេះឡើង នៅមុខវត្តបទុម ដែលមានប្រជាជន ព្រះសង្ឃ និងមានការគាំទ្រពីព្រះមហាក្សត្រខ្មែរផងដែរ ។ គោលបំណងនៃការប្រារព្ធខួបលើកទី៥៩នេះ គឺចង់បញ្ជាក់ប្រាប់កូនខ្មែរឱ្យចងចាំពីប្រវត្តិសាស្ត្រពីអតីតកាល កុំឱ្យកូនខ្មែរជំនាន់ក្រោយដើរជាន់តាមប្រវត្តិសាស្ត្រចាស់ ។ ជាពិសេសថែរក្សាការពារទឹកដីឱ្យគង់វង្ស ពីព្រោះការបាត់បង់ទឹកដីវាពិបាកខ្លាំងណាស់ ហើយខ្ញុំក៏បានស្នើឱ្យរដ្ឋសភាប្រារព្ធទិវានេះ ជាទិវារបស់ជាតិ ប៉ុន្តែខាងសភាមិនបានទទួលយកទេ ។

**+ដោយមើលឃើញទុក្ខលំបាករបស់ខ្មែរកម្ពុជាក្រោមជនបរទេសបានផលិតខ្សែភាពយន្តឡើងធ្វើឱ្យអន្តរជាតិបានដឹង តើខ្សែភាពយន្តនេះឆ្លុះបញ្ចាំងពីបញ្ហាអ្វីខ្លះ ?**

-ខ្សែភាពយន្តនេះល្អណាស់ គឺបានឆ្លុះបញ្ចាំងពីទុក្ខសោករបស់បងប្អូនខ្មែរនៅកម្ពុជាក្រោម ដែលកន្លងមកយើងនិយាយយួនថា បំភ្លើសការពិត ។ ឥឡូវនេះ ? គេនៅតែដាក់ស្លែងមានទាំងកន្លែងដុតខ្មែរ ទាំងរស់រាប់ម៉ឺននាក់ និងវប្បធម៌ អក្សរសាស្ត្រ ដើម្បីបង្ហាញឱ្យបរទេសដឹងព្ធ និងជួយដល់បងប្អូនខ្មែរយើង ។

**+តែខ្សែភាពយន្តនេះ នៅពេលដាក់បញ្ចាំងឱ្យអង្គការសហប្រជាជាតិមើល តើគេមានចំណាប់ អា-រម្មណ៍បែបណា ?**

-តាមអ្នកចូលរួមទស្សនាបានបញ្ជាក់ថា មន្ត្រីអង្គការសហប្រជាជាតិ ក៏ដូចជាជាតិសាសន៍ផ្សេងៗ មានការចាប់អារម្មណ៍ និងរន្ធត់ចិត្តខ្លាំងណាស់ រកអ្វីមកថ្លែងមិនបានឡើយ ។

**+តើអ្នកស្នេហាជាតិយើងក្រោកឡើងប្រឆាំងនឹងពួកយួនយ៉ាងណាខ្លះ ?**

-វីរៈជនស្នេហាជាតិជាច្រើនបានក្រោកឡើង ទាមទារសិទ្ធិសេរីភាព និងទឹកដីកម្ពុជាក្រោមជាបន្តបន្ទាប់ គឺចាប់តាំងពីព្រះបាទជ័យសេដ្ឋាទី២សោយទីវង្គតមកម្ល៉េះ ប៉ុន្តែត្រូវទទួលបរាជ័យ និងមានចំនាស់ជាប្រវត្តិសាស្ត្ររហូតមក ដែលមានខ្មែរកណ្តាលចូលរួមផងដែរ ។ និយាយឱ្យខ្លី នៅថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ១៩៧៦ ពួកកម្ពុជាក្រោមបានបះបោរប្រឆាំងយួន ប៉ុន្តែត្រូវយួនសម្លាប់អស់ជាច្រើនដោយសារគ្មានអាវុធគាំទ្រ ។ ឥឡូវនេះ យើង

( តនៅទំព័រទី៣១ )

## កម្ពុជាក្រោម : និងក្ដីឈឺចាប់...

ក្រោកឡើងប្រឆាំងដែរ ប៉ុន្តែទាមទារសិទ្ធិសេរីភាពក្នុងនាមជាម្ចាស់ប្រទេស ដែលត្រូវតែជិះជាន់ប៉ុណ្ណោះ ។

**+ តើលោកសង្ឃឹមថា អាចទាមទារឯករាជ្យបូរណភាពទឹកដីនៅកម្ពុជាក្រោមទៅថ្ងៃអនាគតបាន ឬទេ ?**

-ទឹកដីកម្ពុជាក្រោមជារបស់ខ្មែរ ហើយខ្មែរយើងមានពាក់កណ្ដាល ។ ចំពោះកម្ពុជាក្រោមជាជនរងគ្រោះយើងមានរដ្ឋាភិបាល ព្រះមហាក្សត្រជាកំម៉ែឪ បើលោកមិនទាមទារជារឿងរបស់លោក ពួកយើងសព្វថ្ងៃចង់បានតែសិទ្ធិសេរីភាពប៉ុណ្ណោះ ។

-បណ្ដារដ្ឋមួយចំនួននៅជុំវិញយើង គេអាចទាមទារបានឯករាជ្យនៅលើទឹកដីដែលបាត់បង់នេះ ជាក្ដីសង្ឃឹមមួយដែរ ប៉ុន្តែខ្មែរយើងមិនទាន់ចាត់ទុកខ្មែរក្រោមជាខ្មែរផង ។ ម្យ៉ាងទៀតការតស៊ូកន្លងមក យួនក្ដោបអំណាចនៅកម្ពុជា គឺអាចធ្វើបាបកម្ពុជាក្រោមសព្វបែបយ៉ាងទាំងអស់ ។ ជាមួយគ្នានេះដែរ លោកក៏បានសំណូមពរដល់ខ្មែរគ្រប់រូបឱ្យចេះរួបរួមគ្នាសាមគ្គីគ្នា កុំធ្វើការរើសអើងផ្នែកសាសនា និងអាណិតអាសូរគ្នាផង ហើយវីរបុរសខ្មែរ ស្លាប់អស់យ៉ាងច្រើន ដើម្បីភាសាអក្សរសាស្ត្រ និងទំនៀមទំលាប់ ដូចជា សុកញ៉ា សឺន គុយ ជាដើម ។